**OMI0009**

# មជ្ឈមណ្ឌលឯកសារកម្ពុជា

*ដាវ រ៉ាន់ ភេទស្រី (រស់)*

*តួនាទីៈ ប្រធានពេទ្យត្រាំកក់ និងប្រធាននារីរោងចក្រតម្បាញ*

*សម្ភាសជាមួយឈ្មោះ ដាវ រ៉ាន់ អាយុ៦៤ឆ្នាំ ក្រៅប្រវត្តិរូប*

*មុខងារសព្វថ្ងៃៈ អនុប្រធានភូមិស្វែងពណ៌*

*រស់នៅភូមិស្វែងពណ៌ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ*

*ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨*

*សម្ភាសដោយៈ ហ៊ិន សុធានី*

***ផ្នែក«ក»***

ធានី ៖ ពួកខ្ញុំមកពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងដែលប្រមូលឯកសារនៅចន្លោះឆ្នាំ១៩៧៥ដល់៧៩ ។ ហើយកាលប្រមូលឯកសារទាំងអស់នេះទុកជាប្រវត្តិសាស្ត្រ ហើយនឹងជាការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ។ ហើយពួកខ្ញុំមកនេះគ្រាន់ចង់ដឹងពីប្រវត្តិលោកយាយដែលឆ្លងកាត់សម័យខ្មែរក្រហមយ៉ាងម៉េច ។ ជាពិសេសនោះគឺថា ចង់ដឹងថាតើសម័យនឹងលោកយាយបានធ្លាប់ធ្វើអំពើល្អ ឬបានជួយដល់ជន ដូចថាប្រជាជនថ្មី ឬជួយឲ្យជាចំណីអាហារអីដល់ពួកគាត់ឲ្យបានមានជីវិតអញ្ចឹង ។ ចង់សួរលោកយាយមានឈ្មោះអីដែរ?

រ៉ាន់ ៖ ខ្ញុំឈ្មោះ ដាវ រ៉ាន់ ។

ធានី ៖ ដាវ រ៉ាន់?

រ៉ាន់ ៖ ចា៎ស!

ធានី ៖ ហើយលោកយាយឆ្នាំនឹងអាយុប៉ុន្មានហើយ?

រ៉ាន់ ៖ ៦៤ ។

ធានី ៖ មានស្រុកកំណើតនៅណា?

រ៉ាន់ ៖ ស្រុកកំណើតខ្ញុំនៅ ស្រុកត្រាំកក់ ។

ធានី ៖ នៅភូមិ ឃុំអីដែរ?

ភ៉ន់ :   ភូមិជាងទង ។

ធានី :   ឃុំ?

ភ៉ន់ :   អូ!មិនមែនភូមិ ឃុំទេជាងទង ។

ធានី :   ឃុំ?

ភ៉ន់ :   ចា៎ស ។

ធានី :   ចុះដល់ពេលភូមិ?

ភ៉ន់ :   ភូមិទទឹងថ្ងៃ ។

ធានី :   ខេត្ត?

ភ៉ន់ :   ខេត្តតាកែវ ។

ធានី :   ហើយសព្វថ្ងៃលោកយាយរស់នៅកន្លែងណាដែរ?

ភ៉ន់ :   នេះហ៎! គេហៅភមិស្វែងពណ៌ ។

ធានី :   ភូមិស្វែងពណ៌?

ភ៉ន់ :   ចា៎ស!

ធានី :   ឃុំអីដែរ?

ភ៉ន់ :   ឃុំត្រពាំងតាវ ។

ធានី :   ស្រុក?

ភ៉ន់ :   ស្រុកអន្លង់វែង ខេត្តឧត្ដរមានជ័យ ។

ធានី :   លោកយាយ ឪពុកលោកយាយឈ្មោះអីគេដែរ?

ភ៉ន់ :   ឪពុកខ្ញុំស្លាប់ហើយ ។

ធានី :   ចា៎ស! គាត់ឈ្មោះអីដែរ?

ភ៉ន់ :   ឈ្មោះ ជៀវ នឹម ។

ធាន់ :   ហើយចុះម្ដាយ?

ភ៉ន់ :   ឈ្មោះគុប ខែល ។

ធានី :   គាត់នៅរស់?

ភ៉ន់ :   ស្លាប់ទាំងអស់ ។

ធានី :   ពេលណាដែរ?

ភ៉ន់ :   គាត់ស្លាប់នៅនេះ ។

ធានី :   នៅឆ្នាំប៉ុន្មាន?

ភ៉ន់ : ស្លាប់ ម៉ែខ្ញុំស្លាប់ឆ្នាំ៨០អី!៨២ អី!២០០២ ។

ធានី : ចុះឪពុក?

ភ៉ន់ : ឪពុកស្លាប់ ហ៉េ!យូរឆ្នាំហើយ១៩០០ ឆ្នាំប៉ុន្មានទេ ភ្លេចឆ្នាំហើយ យូរពេលហើយ ។ គាត់ស្លាប់តាំងពីមុននោះ ។

ធានី : ចុះលោកយាយមានបងប្អូនប៉ុន្មាននាក់?

ភ៉ន់ : បងប្អូន៩នាក់ ។

ធានី : ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ភ៉ន់ : ស្រី៧ ប្រុស២ ប៉ុនស្លាប់ខ្លះហើយ ។

ធានី : ស្លាប់ប៉ុន្មាននាក់?

ភ៉ន់ : ស្លាប់២ អី!ស្លាប់៣ ។

ធានី : ស្លាប់៣?

ភ៉ន់ : ចា៎ស! ស្លាប់៣ ស្លាប់៤នោះ ។

ធានី : ស្រី ឬក៏ប្រុស?

ភ៉ន់ : ប្រុស១ ស្រី២ ស្រី៣ ។

ធានី : អញ្ចឹងទាំងអស់៤ មកពីអី?

ភ៉ន់ : នែង! ឈឺ ។

ធានី : ឈឺ សម័យយើង ឬក៏មុន?

ភ៉ន់ : សម័យក្នុងសង្គ្រាម ។

ធានី : សម័យសង្គ្រាម មិនមែនខ្មែរក្រហមទេ?

ភ៉ន់ : ចា៎ស!

ធានី : ទាំង៤នាក់នឹង?

ភ៉ន់ : ចា៎ស! នែក!មួយនោះស្លាប់តាំងពីតូច ហើយមួយទៀតស្លាប់កាលឆ្នាំប៉ុន្មានទេ យើងភៀសខ្លួនទៅនៅជំរុំនោះ ។

ធានី : ហើយ២ទៀតនៅក្នុងសង្គ្រាម?

ភ៉ន់ : ចា៎ស!

ធានី : អញ្ចឹងលោកយាយរៀនបានថ្នាក់ទីប៉ុន្មានដែរ?

ភ៉ន់ : ខ្ញុំរៀនថ្នាក់ទី៧ ។

ធានី : បានថ្នាក់ទី៧?

ភ៉ាន់ :	ចា៎ស!

ធានី :	សម័យពីមុន?

ភ៉ាន់ :	សម័យសង្គម ។

ធានី :	អញ្ចឹងលោកយាយអាចជួយរៀបរាប់នូវសម័យចន្លោះពី៧៥ដល់៧៩ សម័យប៉ុលពតនឹង តើលោកយាយបានធ្វើការអីខ្លះ ហើយបានជួយអ្នកណាគេខ្លះនៅកន្លែងអីអញ្ចឹង ។

ភ៉ាន់ :	ខ្ញុំកាលខ្ញុំនេះ ខ្ញុំនៅខាងពេទ្យ នៅពេទ្យស្រុក ។

ធានី :	ឆ្នាំប៉ុន្មានដែល លោកយាយ?

ភ៉ាន់ :	១៩៧៥ ។

ធានី :	៧៥ ពេលដែលកងទ័ពខ្មែរក្រហមចូលដល់ភ្នំពេញហើយ?

ភ៉ាន់ :	ចា៎ស!

ធានី :	អញ្ចឹងលោកយាយធ្វើពីពេទ្យម៉ង?

ភ៉ាន់ :	ខ្ញុំនៅកន្លែងពេទ្យ ។

ធានី :	អ្នកណាឲ្យយាយធ្វើខាងពេទ្យនឹង?

ភ៉ាន់ :	កាលនឹងមានតាមរយៈហៅថា មានខាងស្រុក មានខាងអីអញ្ចឹងទៅ គេរៀបចំឲ្យយើងធ្វើ ពេទ្យអញ្ចឹងទៅណា នៅគ្រប់គ្រងពេទ្យនឹងទៅ ។

ធានី :	ឈ្មោះអ៎គេលោកយាយ?

ភ៉ាន់ :	កាលនឹងស្រុកត្រាំកក់ ។

ធានី :	ហ្នឹងហើយអ្នកណា ចាត់តាំងយាយធ្វើពេទ្យ?

ភ៉ាន់ :	កាលនឹងឈ្មោះគាត់ស្លាប់ហើយ ឈ្មោះខុម ។

ធានី :	ឈ្មោះខុម?

ភ៉ាន់ :	ចា៎ស!

ធានី :	ហើយគាត់នឹងជាអីគេ?

ភ៉ាន់ :	គាត់នឹងធ្វើការស្រុក ។

ធានី :	មិនមែនជាគណៈស្រុកទេ?

ភ៉ាន់ :	ចា៎ស! ជាគណៈកមការ ។

ធានី :	ហើយយាយទៅធ្វើពេទ្យនឹងប្រហែលជាប៉ុន្មាន?

ភ៉ាន់ :	ខ្ញុំធ្វើ២ឆ្នាំ ។

ធានី :	ធ្វើពេទ្យនឹង ទៅដល់ភ្លាមគេឲ្យយាយធ្វើភ្លាម ឬមួយក៏យាយ?

រ៉ាន់ ៖ ខ្ញុំគ្រាន់តែគ្រប់គ្រងអ្នកជម្ងឺ ជួយមើលថែអ្នកជម្ងឺនឹងណា ។

ធានី ៖ អញ្ចឹងយើងព្យាបាលគាត់ ឬក៏យាយ?

រ៉ាន់ ៖ នែក! មានពេទ្យគេអ្នកបច្ចេកទេសនឹងគេគ្រប់គ្រង គេព្យាបាលទៅ យើងគ្រាន់តែគ្រប់គ្រង ដូចថាមើល ដូចថាខ្វះនេះ ខ្វះនោះ អត់មានចំណីអាហារអីគ្រប់គ្រាន់អី យើងចេះសុំពីនេះ ពីនោះទៅណា ។

ធានី ៖ អញ្ចឹងលោកយាយធ្វើប្រធានពេទ្យ?

 រ៉ាន់ ៖ ចាស!

ធានី ៖ ប្រធានពេទ្យនៅក្នុងទីរួមស្រុកត្រាំកក់នឹងតែម្តង?

 រ៉ាន់ ៖ ចាស!

ធានី ៖ ហើយពេលនៅគ្រប់គ្រងអញ្ចឹង លោកយាយដែលជួយអ្នកណាមើលទៅដូចថាគាត់ឈឺខ្លាំង ដែលនេះលោកយាយ?

រ៉ាន់ ៖ ខ្ញុំនៅកន្លែងរួមអញ្ចឹង បានជួយជារួម ។

ធានី ៖ ជួយរួមយ៉ាងម៉េច?

រ៉ាន់ ៖ ចាស! ដូចថាខ្វះអី ខ្វះម្ហូប ខ្វះបន្លែអញ្ចឹងទៅ យើងដូចថាសុំគេលិចកើតអញ្ចឹងមក យកមក ផ្គត់ផ្គង់អ្នកជម្ងឺនឹងណា ។

ធានី ៖ អញ្ចឹងដូចយាយសុំពីណាមកវិញ?

រ៉ាន់ ៖ សុំតាមភូមិតាមអីអញ្ចឹងទៅ ។

ធានី ៖ អញ្ចឹងយើងមើលទៅលើសម្ភារៈដែលខ្វះនឹងទេ យាយពេលដែលជួយនឹង នឹងថា?

រ៉ាន់ ៖ ដែលពេលឈឺអី ថ្នាំសង្កូវអីអញ្ចឹង យើងដឹងថាអត់ថ្នាំអស់សង្កូវអី យើងស្នើតាមរយៈគេ អញ្ចឹងទៅណា ។

ធានី ៖ អានឹងគឺថា ជាភារកិច្ចរបស់យាយ ឬយាយគិតថាគួរតែជួយអ្នកទាំងអស់នឹង?

រ៉ាន់ ៖ ចាស! យើងជួយអ្នកទាំងអស់នឹង ។

ធានី ៖ តាមពិតខាងគេ ដូចថាខាងថ្នាក់លើអីគេអត់មានឲ្យយើងធ្វើអញ្ចឹងទេ?

រ៉ាន់ ៖ នែក! ថ្នាក់លើគេមានឲ្យយើងធ្វើដែរ ប៉ុន្តែយើងធ្វើដូចថាចិត្តយើងដូចថាអាណិតអាសូរអ្នក ពេទ្យនឹង ដូចថាមានជម្ងឺឈឺហើម ឈឺអីអញ្ចឹង យើងចេះតែអាណិតយើងចេះតែជំរុញចិត្ត ខ្លួនយើងនឹង ចេះតែដើរសុំគេអញ្ចឹងទៅណា ដើម្បីយកមកជួយផ្គត់ផ្គង់អ្នកដែលឈឺ ។

ធានី ៖ អញ្ចឹងពេលសុំម្តងៗ ព្រោះអីធម្មតាគេមិនមានកម្រិតឲ្យយាយយកប៉ុន្មានៗ ព្រោះយាយ ជាប្រធានពេទ្យអញ្ចឹង?

ភ៉ាន់ ៖ យើងសុំគេតាមដាក់ស្តែង បានជ្រូកក៏បានមក បានមាន់ឬក៏បានបន្លែអញ្ចឹងណា ។

ធានី ៖ អញ្ចឹងយាយខាង តែគ្រប់គ្រងខាងម្ហូបអាហារទេ ក្រៅពីខាងម្ហូបអាហារអត់ទេ?

ភ៉ាន់ ៖ ចា៎ស! ផ្គត់ផ្គង់អ្នកឈឺ ។

ធានី ៖ ហើយអញ្ចឹងដល់ពេលលោកយាយ គ្រប់គ្រងនៅនឹងប្រហែលបានប៉ុន្មាន បានគេផ្លាស់ចេញទៅវិញ?

ភ៉ាន់ ៖ ខ្ញុំនៅ២ឆ្នាំ ។

ធានី ៖ ២ឆ្នាំ?

ភ៉ាន់ ៖ ចា៎ស!

ធានី ៖ ហើយនៅក្នុងអំឡុង២ឆ្នាំនឹង លោកយាយធ្លាប់មានដូចជាបានអញ្ជើញទៅកន្លែងណា ឬបានជួយអ្នកណាអ៊ីមួយទេ?

ភ៉ាន់ ៖ ជួយដូចខ្ញុំនិយាយអញ្ចឹង វាបានជួយក្នុងមន្ទីរពេទ្យ ជួយអ្នកជម្ងឺរួមនៅក្នុងពេទ្យនឹងឯងទាំងអស់ ។

ធានី ៖ ហើយជួយនឹង ជួយដោយយ៉ាងម៉េច?

ភ៉ាន់ ៖ ជួយដូចថាឲ្យយកមក ឲ្យហូបចុកអីបានគ្រប់គ្រាន់សម្រាប់ឲ្យជាឆាប់ ឲ្យអីអញ្ចឹងណា ។

ធានី ៖ ចុះនៅពេទ្យផ្សេងៗធ្វើដូចលោកយាយដែរអត់ទេ?

ភ៉ាន់ ៖ កន្លែងគេផ្សេងៗ មានតាមឃុំ ពេទ្យឃុំអីគេអញ្ចឹងដែរ ។

ធានី ៖ ប៉ុន្តែធ្វើដូចលោកយាយដែរ?

ភ៉ាន់ ៖ គេធ្វើខ្លះ អត់ខ្លះអញ្ចឹងដែរ ប៉ុនតែខ្ញុំៗដូចថាដីដែលច្រើនឃុំ ដល់អញ្ចឹងខ្ញុំសុំខាងនេះម្តង សុំខាងនោះម្តង ដើម្បីយកមកផ្គត់ផ្គង់អ្នកជម្ងឺណា ។

ធានី ៖ អញ្ចឹងបានន័យថាភាគច្រើនអ្នកជម្ងឺ ដែលគេងនៅពេទ្យលោកយាយនឹង គឺសុទ្ធតែបានហូបគ្រប់គ្រាន់ហើយ ផ្គត់ផ្គង់អាហារ?

ភ៉ាន់ ៖ ចា៎ស! ខ្លះអត់ចង់ចេញទេ ដូចថាបានហូបបានចុកអីអញ្ចឹងដូចថា ហើយមួយណាក៏ស្រឡាញ់ខ្ញុំដែរ ។

ធានី ៖ លោកយាយចាំឈ្មោះគាត់ទេ?

ភ៉ាន់ ៖ វាអត់ចាំ ។

ធានី ៖ គាត់អ្នកស្រុកនឹងដែរ ហើយក៏?

ភ៉ាន់ ៖ នែក! កាលនោះវាចំរុះ មន្ទីរវាមកចំរុះគ្រប់ភូមិ គ្រប់ឃុំអញ្ចឹង ។

ធានី ៖ យាយក្តាប់រួមម៉ាស្រុកនឹង?

ភ៉ន់ ៖ ចា៎ស! ពេទ្យ ។

ធានី ៖ ពេទ្យស្រុក?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ អានឹងគេហៅតំបន់ ឬក៏ស្អីកន្លែងពេទ្យនឹង?

ភ៉ន់ ៖ គេហៅពេទ្យស្រុកអញ្ចឹងម៉ង ។

ធានី ៖ ពេទ្យស្រុកត្រាំកក់អញ្ចឹង?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ ចុះប្រធានលើយាយជាអ្នកណា?

ភ៉ន់ ៖ ប្រធានគេនៅតាមខេត្ត តាមអីទៀត គេមានរបស់គេអញ្ចឹងណា ។

ធានី ៖ ឈ្មោះអីដែរយាយ ឈ្មោះគាត់?

ភ៉ន់ ៖ តាមខេត្តនោះខ្ញុំមើលដឹងឈ្មោះអីទេ កាលនោះខ្ញុំគ្រប់គ្រង ភ្លេចឈ្មោះខ្លះហើយខ្ញុំ វាយូរឆ្នាំពេកនោះ ។

ធានី ៖ តែងតាំងយាយ?

ភ៉ន់ ៖ នែក! ខ្ញុំដូចខ្ញុំនិយាយមិញអញ្ចឹង ហ្នឹងខាងស្រុកគេៗរៀបរយណា ។

ធានី ៖ ដល់ពេលគេប្រធានគ្រប់គ្រងពីលើយាយ អត់ចាំឈ្មោះទេ?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ ហើយដល់ពេលយាយនៅបាន២ឆ្នាំអញ្ចឹង ម៉េចបានយាយត្រូវផ្លាស់ប្តូរវិញ?

ភ៉ន់ ៖ ខ្ញុំមកនៅកន្លែងរោងចក្រវិញម្តង រោងចក្រតម្បាញ ។

ធានី ៖ នៅឆ្នាំប៉ុន្មានដែរ យាយ?

ភ៉ន់ ៖ ៧៥ ៧៦ ៧៧ ។

ធានី ៖ ៧៧នៅរោងចក្រតម្បាញ?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ នៅកន្លែងនឹងយាយធ្វើអីទៅ?

ភ៉ន់ ៖ ខ្ញុំទៅ ព្រោះនៅកន្លែងនឹងគេមានរោងចក្រអីនឹង មានដូចថាមានស្រីមានប្រុសអញ្ចឹងទៅណាអញ្ចឹងខ្ញុំទៅនឹងទៅមើលខាងស្រីៗ ដូចថាខាងតម្បាញខាងអីអញ្ចឹង ។

ធានី ៖ អានឹងគេហៅអីគេ ពេលនឹង?

ភ៉ន់ ៖ អានឹងគេហៅគេដាក់រោងចក្រតម្បាញ ។

ធានី ៖ មែនគេហៅយាយ មានឯរគេហៅយ៉ាងម៉េច?

ភ៉ន់ ៖ អើ! កាលនោះគេហៅម៉េច គ្រាន់ប្រធានគ្រប់គ្រងនារីអញ្ចឹងទៅ។

ធានី ៖ ប្រធានគ្រប់គ្រងនារីអញ្ចឹង?

ភ៉ន់ ៖ ចា៎សៗ។

ធានី ៖ ប៉ុន្មាននាក់ទៅ យាយគ្រប់គ្រង?

ភ៉ន់ ៖ អឺ! ដូចក្មេងដែរ ច្រើនដែលរាប់រយនឹង នារីៗ។

ធានី ៖ នៅណាទៅរោងចក្រនឹង?

ភ៉ន់ ៖ នៅតាកែវ។

ធានី ៖ នៅខេត្តតាកែវនឹងម៉ង?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ នៅទីរួមខេត្តនឹង?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ ហើយនៅនឹង យាយធ្លាប់បានជួយអ្នកណា?

ភ៉ន់ ៖ ខ្ញុំជួយក៏ជួយតែក្នុងរួមអញ្ចឹងទៀត ព្រោះគ្រប់គ្រងរួមអញ្ចឹងដល់ក្មេងស្រីៗនង ដូចថាគ្នាខ្វះខោអាវស្លៀកពាក់ស្អី ក៏ស្បៀងអាហារអីអញ្ចឹងទៅ ខ្ញុំចេះតែរត់រកគេក្រៅជួយអញ្ចឹងទៅ ខ្វះសំលៀកបំពាក់អីអញ្ចឹង។ ហើយគេអ្នកដែលគ្រប់គ្រងលើខ្ញុំទៀតនោះ អានោះគេផ្សេងទៀត ខាងបុរសគេគ្រប់គ្រងរួមលើយើងទៀតណា យើងគ្រាន់តែម៉ាផ្នែកណាសម្រាប់ខាងនារីទេ។

ធានី ៖ ម៉េច ពេលដែលយាយជយនឹង ជួយជាយ៉ាងម៉េច?

ភ៉ន់ ៖ ជួយដូចថាឥឡូវយើងនៅក្នុងនឹង បើឃើញនារីៗនឹងខ្វះខាតខាងសំលៀកបំពាក់ខាងអីអញ្ចឹងទៅ យើងទៅជួយប្រធានរួមគេអញ្ចឹងណា យើងគ្រាន់ស្នើថាឥឡូវអ្នកដែលអត់ស្លៀកពាក់នឹងមានចំនួនប៉ុននេះ ប៉ុននោះអ្នកអីអញ្ចឹងទៅ សុំឲ្យខាងគេនឹងគេជួយដោះស្រាយជាសំលៀកបំពាកឲ្យអញ្ចឹង។

ធានី ៖ ចុះសំលៀកបំពាក់ មានស្រាប់ៗរបស់នារីនឹងស្លៀកម៉ង យាយនោះ?

ភ៉ន់ ៖ ចា៎ស! គេកាត់គេដេរ ក្រណាត់។

ធានី ៖ ហើយប្រធានរបស់លោកយាយនឹង ប្រធានធំនឹងគាត់ឈ្មោះអីដែរ?

ភ៉ន់ ៖ ឈ្មោះយោល។

ធានី ៖ យោល ប្រធានរោងចក្រតម្បាញនឹង?

ភ៉ន់ ៖ ចា៎ស!

ធានី ៖ ហើយគាត់មកពីណាវិញ?

រ៉ាន់ ៖ ខ្ញុំអត់សួរក្តាប់ប្រវត្តិគាត់បានដែលនឹង ប៉ុនគាត់ស្លាប់ហើយ ។

ធានី ៖ លោកយាយថាម៉េច បានលោកយាយផ្លាស់មកធ្វើជាខាងប្រធាននារីតម្បាញនឹងវិញ បើមុនលោកប្រធានពេទ្យ?

រ៉ាន់ ៖ ចាស! កាលដែលក្រោយមកវាចេះ ខ្ញុំគេផ្លាស់ឲ្យមកនៅគ្រប់គ្រងនារីខាងរោងចក្រនឹងម្តង ។

ធានី ៖ ម៉េចបានគេផ្លាស់អញ្ជើងយាយ?

រ៉ាន់ ៖ អានឹងតាមសំរូវការរបស់អង្គការគេ ។

ធានី ៖ យាយដឹងមូលហេតុទេ?

រ៉ាន់ ៖ ខ្ញុំមូលហេតុមិនបានដឹង ប៉ុនគ្រាន់ថាគេត្រូវឲ្យមកអញ្ជើងក៏មកៗ ។

ធានី ៖ អត់បានសួរនាំគេដែរ?

រ៉ាន់ ៖ អត់ ។

ធានី ៖ ចុះកាលនឹងអ្នកណា អ្នកឲ្យយាយមក?

រ៉ាន់ ៖ កាលនឹង អ្នកដែលរៀបចំខ្ញុំឲ្យមកៗនៅនឹង ។

ធានី ៖ អ្នកណាគេ?

រ៉ាន់ ៖ ដែលឈ្មោះខុមមិញនឹង ដែលកាលរៀបចំខ្ញុំនឹង រៀបចំនៅស្រុកនឹង អឺ!នៅពេទ្យនឹង ។

ធានី ៖ ហើយគាត់នឹង ដឹងមានងារជាអី បានអាចរៀបចំលោកយាយបាន?

រ៉ាន់ ៖ គាត់នឹងគណៈកម្មការស្រុកគេដែរ ។

ធានី ៖ គណៈកម្មការស្រុក?

រ៉ាន់ ៖ ចាស!

ធានី ៖ ស្រុកត្រាំកក់នឹង?

រ៉ាន់ ៖ ចាស!

ធានី ៖ បានហើយយាយទៅ យាយនៅនឹងម៉េចបានមានដូចថាបញ្ហាពីណា ឬក៏គេឲ្យយាយត្រូវតែធ្វើអញ្ជើង ឬមួយក៏យាយគិតថា ធ្វើដូចជាជួយដល់នារីឲ្យមានសំលៀកបំពាក់ដោយខ្លួនឯង?

រ៉ាន់ ៖ នែក! កាលពេលយើងទៅនឹង យើងឃើញៗថាខ្វះខាតខ្វះនារីអីអញ្ជើងទៅ ក៏យើងមានទឹកចិត្តថារកដោះស្រាយ ដល់អញ្ជើងខ្ញុំស្នើប្រធានគេទៅ ។

ធានី ៖ គេអនុញ្ញាតិឲ្យដែរ?

រ៉ាន់ ៖ គេឲ្យ ។

ធានី ៖ ប៉ុន្មានដង ជួយស្នើម្តងៗ?

រ៉ាន់ :   ២-៣ដងដែរ ហើយទីញឹកដែរ ប៉ុនគ្រាន់ថាម្តងអ្នកនេះ ម្តងអ្នកនោះអញ្ចឹងណា ។

ធានី :   យាយចាំឈ្មោះគាត់ទេ?

រ៉ាន់ :   អឺ! ដូចអត់ចាំ វាបែកខ្ញែកគ្នាអស់ទៅ ។

ធានី :   តែម្តងអ្នកនេះ ម្តងអ្នកនោះអញ្ចឹង គឺជួយតែម្នាក់ៗទេ?

រ៉ាន់ :   ជួយដូចថាឥឡូវ៤-១០នាក់អញ្ចឹងខ្វះហើយណា ដល់អញ្ចឹងលើសុំគេ៤-១០នាក់អញ្ចឹងទៅ ដល់ពេលគេឲ្យ៤-១០នាក់នឹង អ្នកផ្សេងក្រោយទៀតវាអត់ទៀត អញ្ចឹងយើងសុំគេបន្ត អញ្ចឹងទៅ ។

ធានី :   អានឹងយាយ ដូចថាគេខាងពួកគាត់នឹងមកប្រាប់យាយថា ខ្វះហើយអញ្ចឹង?

រ៉ាន់ :   ចាស!

ធានី :   ប្រាប់ហើយបានយាយទៅស្នើសគេ?

រ៉ាន់ :   ចាសៗ ស្នើសុំប្រធានគេអញ្ចឹងណា ។

ធានី :   នៅធ្វើការនឹងគេធ្វើអីខ្លះ?

រ៉ាន់ :   នៅនឹងខ្ញុំទៅនឹងគ្រប់គ្រងខាងរោងចក្រត្បាញៗជាក្រណាត់ ត្បាញជាមុង ចាស! ។

ធានី :   អញ្ចឹងបានក្រណាត់នៅនឹងហើយ ចំបាច់ទៅលើកសុំគេទៅអីទៀត?

រ៉ាន់ :   សុំគេនឹង ចុះបើយើងនៅក្រោមគេ ទាល់តែសុំគេ បានគេដោះស្រាយបាន ។

ធានី :   ប៉ុន្តែក្រណាត់យើងធ្វើនៅនឹងហើយ?

រ៉ាន់ :   ចាស! ក្រណាត់ធ្វើនៅនឹង ដល់ហើយគេមានជាងគេកាត់ដេរឲ្យអញ្ចឹងណា ហើយបើយើង គ្រប់គ្រងដែរ ប៉ុនយើងអត់ស្នើប្រធានគេ វាមិនបានដែរ ។

ធានី :   ជួយដូចថាជួយនឹងជួយ៤-១០ដងនឹង គឺជួយយ៉ាងម៉េច?

រ៉ាន់ :   ជួយដូចថា ឥឡូវម្តងអញ្ចឹងថា៤-១០អញ្ចឹងដែលខ្វះ ។

ធានី :   ចង់និយាយថា ម៉ាឆ្នាំអញ្ចឹងយើងត្រូវតែកំណត់ថាជួយប៉ុននឹង ឬមួយក៏តាមដែលគាត់ថាសុំ ជួយ?

រ៉ាន់ :   តាមដែលឃើញការខ្វះខាត ខ្វះគ្នាដាច់ដូចថាកំណត់ ម៉ាឆ្នាំម៉ាកំប្លេរពីរកំប្លេរ ប៉ុនបើគ្នាស្លៀក អត់គ្រប់ ។ ចាស! ដល់អញ្ចឹងយើងសុំប្រធានគេនឹងបន្ថែមឲ្យអញ្ចឹងណា ។

ធានី :   អញ្ចឹងតាមពិតខាងគេនឹងគេកំណត់ថាមួយឆ្នាំប៉ុន្មានកំប្លេរ?

រ៉ាន់ :   ពីរកំប្លេរ ។

ធានី :   ដល់ពេលយាយបានឃើញខ្វះអញ្ចឹងទៅ ក៏សុំបន្ថែមដើម្បីឲ្យ?

រ៉ាន់ :   ឲ្យស្លៀកពាក់ ។

ធានី ៖ ហើយដូចថាមានបញ្ហាពីណាពីណែឲ្យប្រាប់ថា យើងត្រូវធ្វើអញ្ចឹង ឬមួយយ៉ាងម៉េច?

ភ៉ាន់ ៖ ព្រោះបញ្ហាអត់មានអ្នកបញ្ហាដែរទេ ព្រោះយើងទៅយើងឃើញហើយ ឃើញការខុះខាត ហើយប្រធានគេនៅនឹង គេគ្រប់គ្រងរួមម៉ារោងចក្រនឹង គេមើលអត់សព្វ ដល់យើងមើលម៉ាជ្រុង ដែលយើងនៅមើលនឹង ឃើញសព្វអញ្ចឹង យើងចេះតែស្ទើបន្ថែមឲ្យគ្នាទៅ ។

ធានី ៖ បន្ទាប់មកទៀតទៅណាទៀត មានទៅណាទៀតទេយាយ បន្ទាប់ពីនៅរោចក្រនឹងគេធ្វើហើយទៅណា?

ភ៉ាន់ ៖ ខ្ញុំនៅរោងចក្រនឹងរហូត ។

ធានី ៖ រហូត?

ភ៉ាន់ ៖ ចា៎ស!

ធានី ៖ រហូតដល់ពេលណាទៅ?

ភ៉ាន់ ៖ ដល់យើងវិបែកបាក់គ្នា កាលសង្គ្រាមនឹងក៏ចេញមកព្រំដែនមកនឹង ។

ធានី ៖ អញ្ចឹងបានន័យថា អញ្ចឹងលោកយាយធ្វើការតែពេលនៅឆ្នាំ៧៥ធ្វើប្រធានពេទ្យទេ ហើយដល់ពេលឆ្នាំ៧៧បានមកធ្វើកងនារីតម្បាញនឹង?

ភ៉ាន់ ៖ ចា៎ស!

ធានី ៖ ហើយអត់មាន ចុះលោកយាយឃើញមានអ្នកធំៗណាអី គាត់មកទស្សនកិច្ចអីនៅនឹង?

ភ៉ាន់ ៖ ធំៗដូចរោងចក្រ មិនសូវឃើញមានអ្នកចូលដែរ មិនសូវឃើញមានអ្នកចូលទេ ។

ធានី ៖ ហើយនៅរោងចក្រនឹង ពេលគេត្បាញម្តងៗគេយកទៅណា?

ភ៉ាន់ ៖ ត្បាញនឹងយើងយកសម្រាប់ នែក!ផ្គត់ផ្គងកម្មករក្នុងនឹងម៉ាចំនួន ហើយម៉ាចំនួនទៀតដូចថាខាងប្រធានគេចាត់ចែងគេឲ្យទៅនេះទៅនោះអីអានឹងនៅគេប្រធានចាត់ចែងណា ។

ធានី ៖ ហើយគាត់ លោកយាយមិញមានខាងអង្គភាពនារី ខាងលោកយាយគ្រប់គ្រង ចុះខាងអង្គភាពបុរសនឹង គាត់នឹងជាអ្នកណា?

ភ៉ាន់ ៖ ហ្នឹងខាងប្រធានគេនឹងគេគ្រប់គ្រង ។

ធានី ៖ គាត់ឈ្មោះអ៎ដែរ?

ភ៉ាន់ ៖ ឈ្មោះតាយោល ។

ធានី ៖ តាយោលនឹង អញ្ចឹងបានន័យថាលោកយាយជាប្រធានជាមួយតាយោលនឹង?

ភ៉ាន់ ៖ នែក! ខ្ញុំម៉ាផ្នែកខាងនារី គេនឹងគ្រប់គ្រងរួម ។

ធានី ៖ រួមផង គ្រប់គ្រងខាងបុរសផង?

ភ៉ាន់ ៖ ចា៎ស!

ធានី ៖ អញ្ចឹងលោកយាយបានជួយ មានអីផ្សេងទៀតទេ ដែលលោកយាយធ្លាប់ជួយពួកគាត់?

វ៉ាន់ ៖ ជួយស្បៀងអាហារក៏ជួយខ្លះ ដូចថាពេលអត់ឃ្លានអញ្ចឹងទៅ យើងស្គាល់កន្លែងនេះ កន្លែងនោះអីអញ្ចឹងទៅ ដូចថាយើងសុំជាពោត សុំជាអីអញ្ចឹងខ្លះយកមកផ្សំជាមួយបាយជាមួយអីនឹង ហើយអន្តរភាពនឹងយើងធ្វើស្រូវដែរ ។

ធានី ៖ មានធ្វើស្រូវដែរ?

វ៉ាន់ ៖ ចាស! ធ្វើស្រែ ដល់អញ្ចឹងទៅយើងបានហូបចុកសរុប ។

ធានី ៖ អញ្ចឹងលោកយាយដឹកនាំពួកគាត់ធ្វើស្រែផង ហើយធ្វើត្បាញនឹងដែរ?

វ៉ាន់ ៖ ចាស! ធ្វើស្រែនឹងខាងប្រធានគេអ្នកដឹកនាំ ប៉ុនដល់ត្រូវបានការកម្លាំងស្ទូងដកអី គេសុំនារីទៅជួយស្ទូងអញ្ចឹងណា ។

ធានី ៖ អញ្ចឹងភាគច្រើនលោកយាយជួយគាត់នឹង ពេលណាដែរ?

វ៉ាន់ ៖ ជួយខែធ្វើស្រែ ។

ធានី ៖ ជួយយ៉ាងម៉េច?

វ៉ាន់ ៖ ជួយដូចថាខ្លះសំលៀកបំពាក់អី ដល់អញ្ចឹងខែធ្វើស្រែអញ្ចឹង គ្នាខ្លះស្លៀកពាក់អញ្ចឹង ថាខ្ញុំស្នើសុំប្រធានគេអញ្ចឹងណា ។

ធានី ៖ នៅកន្លែងទីរួមខេត្តតាកែវនឹងម៉ង?

វ៉ាន់ ៖ ចាស!

ធានី ៖ នៅក្បែររោងចក្រនឹងដែរ លោកយាយស្រែនឹង?

វ៉ាន់ ៖ ធ្វើស្រែនឹង នៅឆ្ងាយដែរ ប្រហែលម៉ាគីឡូ ពីរគីឡូដែរដឹង ។

ធានី ៖ ម៉ាគីឡូ ពីរគីឡូពីរោងចក្រនឹង?

វ៉ាន់ ៖ ចាស!

ធានី ៖ ហើយដូចថាលោកយាយពេលដែល អញ្ចឹងឲ្យធ្វើស្រែពីឆ្នាំ៧៧ធ្វើស្រែដែរអត់?

វ៉ាន់ ៖ ធ្វើ ។

ធានី ៖ ធ្វើដែរ?

វ៉ាន់ ៖ ចាស!

ធានី ៖ អញ្ចឹងឲ្យតែរដូវធ្វើស្រែ គឺត្រូវធ្វើស្រែ?

វ៉ាន់ ៖ ចាស!

ធានី ៖ ខែប្រាំង?

វ៉ាន់ : ខែ អត់ទេ ខែវស្សានឹងយើងធ្វើស្រែ ធ្វើស្រែរួចយើងច្រូតកាត់រួចហើយ យើងធ្វើរោង ចក្រវិញទៅ ប៉ុនទៅនឹងក៏អត់ដាច់ដែរ ប្តូរគ្នា ដូចខ្ញុំនិយាយអញ្ចឹង ឧទាហរណ៍ថា១០នាក់ទៅ ១០នាក់មកអញ្ចឹង អត់ឲ្យដាច់ការងារ ។

ធានី : អញ្ចឹងពេលដែលយាយបញ្ជូនម្តង ព្រោះលោកយាយគ្រប់គ្រងម៉ាសារប៉ុន្មាន១០០?

វ៉ាន់ : អាច១០០ដែរ កាលនឹងច្រើនដែរ ។

ធានី : ព្រោះយាយថាម៉ាកងនារីប៉ុន្មានរយទៅ?

វ៉ាន់ : ១០០ ។

ធានី : ១០០នាក់?

វ៉ាន់ : ចាស!

ធានី : ហើយយាយបែងចែកយ៉ាងម៉េច ដូចថាអ្នកណាត្រូវធ្វើស្រែ អ្នកណាគេ?

វ៉ាន់ : អ្នកណាត្បាញៗទៅ អ្នកណាដែលត្រូវធ្វើស្រែអញ្ចឹងក៏ទៅៗ ប្តូរគ្នាម្តងម្នាក់អញ្ចឹងណា ។

ធានី : នេះបែងចែកយ៉ាងម៉េច?

វ៉ាន់ : បែងចែកថាឥឡូវ១០នាក់ទៅធ្វើស្រែ ដល់នៅ៩០នាក់យើងដំណើរការធ្វើស្រែនឹងដដែល ត្បាញដដែលទៅ អា១០នាក់នេះមក យើងឲ្យ១០នាក់នោះទៅទៀត ឆ្លាស់គ្នា ។

ធានី : ហើយចុះមិញលោកយាយថា បានជួយពួកគាត់នៅពេលធ្វើស្រែ នៅរដូវធ្វើស្រែ ជួយនឹង ជួយទៅខាងអ្នកធ្វើស្រែ ឬមួយក៏យ៉ាងម៉េច?

វ៉ាន់ : ជួយទាំងអស់ ឲ្យតែអ្នកខ្វះស្បៀកពាក់ ចាស!អ្នកខ្វះគ្នាមិនបានទៅធ្វើស្រែដែរ ប៉ុនវាស្បៀក អត់គ្រប់ណា ម៉ាឆ្នាំ២កំប្លេរ យើងស្បៀកអត់គ្រប់ ។

ធានី : ចុះដូចជាម្ហូបអាហារអី យើងហូបរួមទាំងអស់គ្នាជាមួយកងខាងបុរសដែរ ឬក៏តែម៉ាកងខាង លោកយាយទេ?

វ៉ាន់ : អត់ទេ ហូបដោយឡែកពីគ្នា ប៉ុនដូចគ្រាន់ថាបុរសគេហូបផ្នែកបុរសទៅ នារីហូបខាងនារី អញ្ចឹងណា ។

ធានី : ហូបរួមគ្នា ចង់និយាយថា?

វ៉ាន់ : ប៉ុនចង្ក្រានតែមួយទេ ។

ធានី : ធ្វើរាងពីរលោកយាយ?

វ៉ាន់ : ចាស! ហូបដោយឡែកពីគ្នាផ្នែកខាងនារីៗហូបផ្សេងទៅ ខាងបុរសៗហូបផ្សេងទៅ ប៉ុន ចង្ក្រានឆ្នាំងបាយតែមួយទេ មានអ្នកគេធ្វើអញ្ចុងណា ។

ធានី : ហើយយាយៗអ្នកស្មើទៅរកអានឹង មិនមែនខាងតាយោលអ្នករកទេ?

វ៉ាន់ ៖ អត់ទេ ខាងប្រធានគេជាអ្នករក ។

ធានី ៖ ចុះលោកយាយថាបានជួយរកអាហារឲ្យពួកគាត់ហូប?

វ៉ាន់ ៖ ជួយនឹង ជួយម្ដងម្កាល ។

ធានី ៖ ពេលណាទៅយាយ ដែលបានជួយ?

វ៉ាន់ ៖ នែក! ពេលច្រើនខែវស្សាអញ្ចឹង ។

ធានី ៖ ហើយជួយយ៉ាងម៉េច ជួយរក?

វ៉ាន់ ៖ ដូចថាយើងខ្វះស្រូវហូបមិនគ្រប់អញ្ចឹងទៅ យើងជួយដូចថាមានស្គាល់អ្នកនៅនេះ នោះអី អញ្ចឹងទៅ យើងសុំពោតសុំអីគេខ្លះៗអញ្ចឹងមក យកមកផ្សំគ្នាជាមួយបាយ ។

ធានី ៖ អញ្ចឹងតាយោលនឹងគាត់ដឹងទេ?

វ៉ាន់ ៖ ចា៎ស!

ធានី ៖ គាត់ដឹងរឿងដែលយាយដើរសុំអាហារពីអ្នកផ្សេង ហើយយកមកគ្រប់គ្រង?

វ៉ាន់ ៖ ប្រធាននឹង?

ធានី ៖ ចា៎ស!

វ៉ាន់ ៖ ដឹងដែរតើ ។

ធានី ៖ គាត់អនុញ្ញាតិឲ្យដែរ?

វ៉ាន់ ៖ ចា៎ស!

ធានី ៖ ឬមួយក៏បានមានការអនុញ្ញាតិហើយបានយាយទៅនោះ?

វ៉ាន់ ៖ ចា៎ស! បានយើងទៅរក ។

ធានី ៖ អញ្ចឹងបានន័យថា យាយពិភាក្សា ដូចថាពីរឿងដែលខ្វះអញ្ចឹងហើយ បានយាយទៅប្រាប់ខាងប្រធានហើយ បានលោកយាយទៅរកជួយអ្នកនៅក្នុងនឹងទៅ?

វ៉ាន់ ៖ ចា៎ស! ព្រោះគេប្រធានណា៎ ។

ធានី ៖ ពេលលោកយាយបានជួយ ក៏ដូចជាលោកយាយនៅពេទ្យស្រុកអី បានដើររកអាហាររកអី ដូចនៅខាងនេះអញ្ចឹង តើលោកយាយមានអារម្មណ៍ម៉េចដែរ?

វ៉ាន់ ៖ មានអារម្មណ៍របស់ខ្ញុំយល់ថា ពេលដែលទៅនៅក្នុងអន្តភាពអញ្ចឹងវាជារួម ដល់អញ្ចឹងខ្ញុំនឹកឃើញថា កូនគេក៏ដូចកូនខ្ញុំ ឃើញមានការខ្វះខាត មានការអត់ឃ្លានអញ្ចឹង ហៅថាមនោសញ្ចេតនាមួយគឺអាណិត ។ ព្រោះនឹកថាគ្នាបែកបាក់ម៉ែឪមក មកនៅជុំជាមួយគ្នា នៅជាមួយយើងអញ្ចឹង មិនថាជាម្ដាយអីទេ ប៉ុន្តែគ្រាន់ថាមានការអាណិត មានការស្រណោះគ្នាអញ្ចឹង ដល់ពេលអត់ឃ្លានក៏គ្នាបែកពីម៉ែ ពីឪមកហើយ ។

ធានី ៖ ហើយដូចថាមកដល់សព្វថ្ងៃដែលធ្លាប់ អ្នកដែលលោកយាយបានជួយ ឬអីនឹងមកលេង យាយ ជួបធ្លាប់ជួបគ្នាទេ?

វ៉ាន់ ៖ នែក! មកដល់មកដាច់ឆ្ងាយអញ្ចឹងមានដែរតើ ។

ធានី ៖ មានដែរ?

វ៉ាន់ ៖ ចាស!

ធានី ៖ គាត់នឹងជាអ្នកណា?

វ៉ាន់ ៖ នែក! គាត់នៅស្រុកយើងនោះដែរ ដែលធ្លាប់កូនម៉ែឪអញ្ចឹង ។

ធានី ៖ គាត់ឈ្មោះអីដែរ?

វ៉ាន់ ៖ អឺ! មើលឈ្មោះអីទៅវាច្រើន មកលេង ដល់អញ្ចឹងឯងវាចាស់ទៅវាអត់ចាំឈ្មោះគេនឹង ។

ធានី ៖ ពេលណាលោកយាយ?

វ៉ាន់ ៖ អត់បានចាំឈ្មោះគេ ។

ធានី ៖ គាត់មកលេងប៉ុន្មានដងដែរយាយ?

វ៉ាន់ ៖ គាត់មកលេងម្តង ។

ធានី ៖ ពេលណាទៅ?

វ៉ាន់ ៖ មកយូរដែរហើយ កាលយើងទើបសមាហរណ៍កម្មហើយ ។

ធានី ៖ មកប៉ុន្មាន?

វ៉ាន់ ៖ កាលនឹងទៅលេងឯជុំវិញ ដល់ហើយមកយើងមិនសមាហរណ៍កម្ម ឡប់មកនេះ គេមកលេង បងប្អូនគេផង ។

ធានី ៖ ហើយឃើញលោកយាយក៏?

វ៉ាន់ ៖ ហ្នឹងហើយ ជួបក៏លេងតាមដំណើរនឹងទៅ ។

ធានី ៖ អញ្ចឹងលោកយាយអត់ចាំឈ្មោះគាត់ទេ?

វ៉ាន់ ៖ អត់ចាំទេ ។

ដានី ៖ កម្មករដែលលោកយាយធ្លាប់គ្រប់គ្រងនឹង?

វ៉ាន់ ៖ ចាស! ធ្លាប់ដែលនៅនឹង ចាស!នៅជាមួយខ្ញុំនឹង ។

ដានី ៖ ប៉ុន្មាននាក់?

វ៉ាន់ ៖ មកលេងនោះ បានតែម្នាក់ទេ កាលនឹងនៅ ។

ដានី ៖ គេមកពីខាងណា?

វ៉ាន់ ៖ កាលនឹងនៅ គាត់នឹងនៅតាកែវដែរ ។

ដានី ៖ នៅតាកែវដែរ?

រ៉ាន់ ៖ ចាស! ប៉ុនខ្ញុំអត់ចាំឈ្មោះ ។

ដានី ៖ ឆ្នាំណាៗដែលគេមកលេង?

រ៉ាន់ ៖ មើលកាលនៅជំរុំអូរត្រាវ ឆ្នាំប៉ុន្មានឥឡូវ ។

ដានី ៖ មុនសមាហរណ៍កម្ម?

រ៉ាន់ ៖ ចាស!

ដានី ៖ ប្រហែលជាឆ្នាំ៩០ជាង ឬ៨០ជាង?

រ៉ាន់ ៖ តាមមើលដូចជា៩០ ។ មើល!តាកាលនៅអូរត្រាវឆ្នាំប៉ុន្មាន មុន២០០០ អត់ចាំ ។

ធានី ៖ ប៉ុន្តែពេលគាត់មកលេងនឹង ពេលសមាហរណ៍កម្មលោកយាយមកដល់ភូមិហើយ ឬមួយក៏ទៅលេងនៅជំរុំជាមួយគ្នា?

រ៉ាន់ ៖ លេងនៅជំរុំ ចាស!ដល់មកនេះអត់ ។

ធានី ៖ អញ្ចឹងគាត់បានទៅលេងយាយ?

រ៉ាន់ ៖ ចាស!

ធានី ៖ អញ្ចឹងម៉េចបានលោកយាយមកនៅភូមិនេះវិញ?

រ៉ាន់ ៖ មកសមាហរណ៍កម្ម ។

ធានី ៖ ចុះមុននឹង លោកយាយធ្វើម៉េចបានរត់ទៅដល់ជំរុំ?

រ៉ាន់ ៖ ខ្ញុំកាលនឹងនៅអន្លង់វែង នៅនឹង ។

ធានី ៖ ម៉េចមកដល់នឹង ព្រោះលោកយាយថាមិនទៅធ្វើការនៅខាងតម្បាញ?

រ៉ាន់ ៖ ដែលចុះកាលដល់៧៩យើងមក មិនរត់មក ។

ធានី ៖ រត់មក?

រ៉ាន់ ៖ ចាស! មកគេមកឯងនឹងមក ។

ធានី ៖ កាលនឹងមកជាមួយអ្នកណាគេ?

រ៉ាន់ ៖ មកតាមប្រជាជន មកតាមកងទ័ពដែលគេចេះតែមកៗតាមគេ តាមឯងអញ្ចឹងមក ចាស! មកដល់ព្រំដែននឹងចូលដីថៃនឹង ។

ធានី ៖ ចុះលោកយាយចន្លោះពេលដែលលោកយាយមកតាមផ្លូវនឹង ដែលធ្លាប់ឃើញមានប្រជាជនថ្មីឬអ្នកណាដែលរត់មកហើយ លោកយាយបានជូនគាត់ទៅអីដែរអត់មានទេលោកយាយ?

រ៉ាន់ ៖ អត់ៗជួប ។

ធានី ៖ ជួបតែគ្នាឯង?

រ៉ាន់ ៖ ចាស! អត់មានជួប ។

**ផ្នែក «ខ»**

ធានី ៖ ដូចថាយាយ នៅពេលដែលលោកយាយធ្វើការនឹង លោកយាយ ប្រធានលើកៗតាយោល នឹងអ្នកណាគេ នៅខេត្តតាកែវនឹង?

រ៉ាន់ ៖ ខ្ញុំកាលនឹងដឹងតាយោលមួយនៅកន្លែងអង្គភាពនឹង ។

ធានី ៖ ក្រៅពីនឹង?

រ៉ាន់ ៖ ក្រៅពីនឹង ដែលគេគណៈតំបន់នឹងឈ្មោះសោម ។

ធានី ៖ គណៈតំបន់សោម?

រ៉ាន់ ៖ ចាស!

ធានី ៖ តំបន់ប៉ុន្មានដែរយាយ?

រ៉ាន់ ៖ ចាស! អ្នកធ្វើការ ។

ធានី ៖ តំបន់លេខប៉ុន្មានដែរ?

រ៉ាន់ ៖ អូ! តំបន់កាលនោះគេហៅតំបន់តាកែវ ។

ធានី ៖ តំបន់តាកែវនឹង?

រ៉ាន់ ៖ ចាស! ខេត្តតាកែវ ។

ធានី ៖ អត់មានតំបន់ទេ?

រ៉ាន់ ៖ តំបន់១៣ គេហៅតំបន់១៣ ។

ធានី ៖ នៅភូមិភាគអីគេ កន្លែងនឹងគេហៅភូមិភាគអីគេ?

រ៉ាន់ ៖ ហ្នឹងបើនិយាយទៅនារតី ។

ធានី ៖ ហើយអ្នកណាប្រធានភូមិភាគដែរ?

រ៉ាន់ ៖ នែក! តាសោម ឈ្មោះសោម ។

ធានី ៖ តាសោម ដែលគណៈតំបន់?

រ៉ាន់ ៖ គណៈតំបន់ ។

ធានី ៖ ១៣នឹង?

រ៉ាន់ ៖ ចាស!

ធានី ៖ ដល់ពេលខាងភូមិភាគនារតី យាយអត់ដឹងអ្នកណាគេ?

រ៉ាន់ ៖ ភូមិភាគនារតី តាម៉ុក ។

ធានី ៖ តាម៉ុក?

ភ៉ាន់ : ចា៎ស!

ធានី : លោកយាយដែលឃើញគាត់ទេ?

ភ៉ាន់ : ធ្លាប់តើ ។

ធានី : ហើយគាត់ចុះមកដល់មើលដល់ កន្លែងលោកយាយធ្វើការទេ?

ភ៉ាន់ : ចុះតើ ។

ធានី : ហើយម៉េចដែលមើលទៅ គាត់កាចហើយស្លូត?

ភ៉ាន់ : អឺ! ពិបាកថាគាត់ដែរ បើនិយាយថាកាចក៏ថាបាន និយាយថាស្លូតក៏ថាបាន ព្រោះគាត់បើថាមកឃើញអញ្ចឹងទៅ យ៉េញអត់អីមានអី គាត់ដោះស្រាយឲ្យភ្លាម ហើយត្រង់ថាកាចនោះ បើថាឲ្យអីណាអញ្ចឹង គ្រាន់ដើរចេញ គាត់យកវិញ ឲ្យអ្នកនោះផ្សេងទៀតអញ្ចឹងទៅ ។

ធានី : អញ្ចឹងលោកយាយដែលធ្លាប់ដូចថាទៅកន្លែងតាម៉ុក យករបស់ដូចសុំអីពីគាត់ដែរ?

ភ៉ាន់ : អត់ទេ ខ្ញុំបើព្រោះមានប្រធានគេហើយ ខ្ញុំអត់រំលងទេ ។

ធានី : តាមលំដាប់លដោយយាយនោះ?

ភ៉ាន់ : ចា៎ស!

ធានី : ហើយដល់ពេលយាយនៅជំនាន់នឹង ធ្លាប់ឃើញមានខុសសីលធម៌ឬក៏អីដែរអត់ទេ នៅសម័យនឹង?

ភ៉ាន់ : នៅអង្គភាពខ្ញុំនៅនឹង ខុសសីលធម៌ ខាង?

ធានី : បុរសនារីអី?

ភ៉ាន់ : បុរសនារីអី ដូចអត់មានទេ ។

ធានី : ពេលដែលលោកយាយមកដល់ភូមិនេះនៅឆ្នាំប៉ុន្មាន?

ភ៉ាន់ : មើល! ខ្ញុំមកច្រើនដំណាក់ណាស់ ខ្ញុំមកពី៧៩នោះនៅចូលជុំរុំខ្នងយៃ ។

ធានី : ខ្នងយៃ ហើយម៉េចទៀតទៅ?

ភ៉ាន់ : ដល់អញ្ចឹងមកៗនៅបារាំងធ្លាក់ចក្រីអីអញ្ចឹងទៅ ដល់គេវៃនឹងអញ្ចឹងទៅស្រះកែវ ។

ធានី : ស្រះកែវនៅថៃ?

ភ៉ាន់ : ចា៎ស! នៅជុំរុំណា ។

ធានី : ហើយម៉េចទៀត?

ភ៉ាន់ : ដល់ក្រោយមកគេចេះតែមានគេឯងមកតាមៗព្រំដែននឹងចេះមកនឹងគេឯងមកដល់នេះមក ។

ធានី : ឆ្នាំប៉ុន្មានមកដល់នេះ?

ភ៉ាន់ : មើល! មកដល់នេះខ្ទង់៨៥ ៨៦ហើយដឹង ។

ធានី ៖ ហើយមកដល់សព្វថ្ងៃមានធ្វើការងារអីដែរ មានមុខរបរ?

ភ៉ាន់ ៖ ពល់ថ្ងៃនេះ ខ្ញុំធ្វើភូមិតិចតួចដែរ ។

ធានី ៖ អីគេភូមិដែរ?

ភ៉ាន់ ៖ ធ្វើអនុភូមិ ។

ធានី ៖ ធ្វើអនុភូមិ?

ភ៉ាន់ ៖ ចា៎ស!

ធានី ៖ អនុភូមិ?

ភ៉ាន់ ៖ ភូមិស្មែងពណ៌នឹង ។

ធានី ៖ ហើយលោកយាយដែលធ្លាប់ឮរឿងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ភ៉ាន់ ៖ ឮតើ ។

ធានី ៖ លោកយាយយល់ថាតុលាការនឹងយ៉ាងម៉េចដែរ?

ភ៉ាន់ ៖ យល់ថាម៉េចទេ យល់ថាការកាត់ទោសនឹងវាមិនដឹងជារកយុត្តិធម៌ឃើញពិតប្រាកដ ប៉ុន្តែយ៉ាងណាដែរ វាមិនទាន់ច្បាស់លាស់ដែរ មិនសូវបានអត់មានទូរទស្សន៍អីមើល ។

ធានី ៖ អញ្ចឹងលោកយាយគិតថាតុលាការនឹង អាចថាមានយុត្តិធម៌ដែរអត់?

ភ៉ាន់ ៖ ខ្ញុំថាមានយុត្តិធម៌ ព្រោះមុននឹងការដោះស្រាយអីមួយៗ ខាងមានអ្នកចុះពិនិត្យតាមដានស្រាវជ្រាវបានច្បាស់លាស់ដែរ ។ ចា៎ស! ព្រោះមិនធ្វើដោយតាមអំពើចិត្ត ពិនិត្យបានច្បាស់លាស់ហើយបាន ។

ធានី ៖ លោកយាយគិតថា តុលាការនឹងមានប្រយោជន៍ទេ តុលាការមានប្រយោជន៍អត់សម្រាប់យាយផ្ទាល់ខ្លួន?

ភ៉ាន់ ៖ ប្រយោជន៍នឹង និយាយពីប្រយោជន៍អី?

ធានី ៖ លោកយាយគិត?

ភ៉ាន់ ៖ ខ្ញុំអត់ទាន់យល់សំនួរនឹង ធ្វើពន្យល់តិចមើល ។

ធានី ៖ ចង់សួរពីយោបល់លោកយាយៗ គិតថាពេលដែលគេបង្កើតតុលាការឲ្យមានអញ្ចឹង គិតថាវាមានប្រយោជន៍អត់ បានគេបង្កើតតុលាការនឹង?

ភ៉ាន់ ៖ ចា៎ស! ខ្ញុំយល់ថាការបង្កើតនេះវាជាការត្រឹមត្រូវហើយ ដើម្បីរកយុត្តិធម៌ឲ្យប្រជាពលរដ្ឋ ។

ធានី ៖ លោកយាយមានអីចង់បន្ថែមនូវអ្វីដែលពួកខ្ញុំអត់បានសួរទេ?

ភ៉ាន់ ៖ ឃើញសួរអស់ច្រើនហើយនឹង អត់មានអីថែមទេ ។

ដានី ៖ លោកយាយចង់បន្ថែមម៉ាតិច ដូចថាការពីជំនាន់ចន្លោះ៣ឆ្នាំ លោកយាយដែលធ្លាប់ជួបប្រជាជនថ្មី ឬក៏ប្រជាជនណាដែលធ្លាប់បានជួបលោកយាយ ឬក៏បានរាប់អានជាមួយលោកយាយៗមានរាប់អានជាមួយគាត់?

វ៉ាន់ ៖ ជួបចេះតែជួបហើយ នៅមន្ទីរពេទ្យ ប៉ុនត្រង់ថាឲ្យរាប់អានជាកូនជាចៅជានេះម៉ង វាអត់ហើយណា ចា៎ស! គ្រាន់ថាជួយៗផ្គត់ផ្គង់ម្ហូបអាហារ ជួយថ្នាំសង្កូវអីនឹងដូចថាមានទឹកចិត្តមួយវាសុទ្ធតែខ្មែរ ដល់អញ្ចឹងខ្ញុំជួយខំរកម្ហូប ខំរកបន្លែខំរកស្បៀងខំដើរទាក់ទងគេសុំគេលិចកើតនឹង យកមកដោះស្រាយរួម អត់មានដោះជាបុគ្គលទេ។

ដានី ៖ ប៉ុន្តែអ្នកដែលធ្វើពេទ្យនឹង អ្នកដែលធ្វើការក្នុងនឹងសុទ្ធតែកូនចៅរបស់ប្រជាជននៅមូលដ្ឋាននឹង ឬក៏មានកូនចៅប្រជាជនថ្មីដែល១៧មេសា គេមកឲ្យជម្លៀសមកឲ្យ?

វ៉ាន់ ៖ កាលនឹង បើតាមពិតទៅដូចអត់មានទេ មានតែអ្នកភូមិគេនឹងភូមិក្នុងស្រុកគេនឹង។

ដានី ៖ ចុះដូចជាប្រជាជនថ្មី ដែលគាត់មករស់នៅក្នុងសហករណ៍អី លោកយាយមានដែលជួបគាត់មានធ្លាប់រាប់អានគាត់ ឬក៏ពេលឃើញគាត់ គឺថាធ្លាប់ឲ្យចំណីអាហារអញ្ចឹងដល់ពួកគាត់អីមានដែលអត់?

វ៉ាន់ ៖ ដូចខ្ញុំនិយាយអញ្ចឹង មាននៅក្នុងពេទ្យនឹង គឺខ្ញុំរកឲ្យផ្គត់ផ្គង់ ប៉ុនថាបើឲ្យចាំឈ្មោះ ឲ្យស្គាល់ឈ្មោះក ឈ្មោះខអីអញ្ចឹង ឃើញឲ្យៗអញ្ចឹង។

ដានី ៖ ចុះលោកយាយដូចថាមាន កាលជំនាន់នឹងមានដូចថាគេត្រូវចាប់ ត្រូវអី ដូចថាត្រូវគេចាប់ហើយអញ្ចឹងលោកយាយដឹង ដូចថាអាណិតអីអញ្ចឹងទៅជួយឲ្យបានគាត់រួចខ្លួនវិញ មានដែរអត់?

វ៉ាន់ ៖ អត់ដែលជួប។

ដានី ៖ អត់ដែលបានជួប?

វ៉ាន់ ៖ ចា៎ស!

ដានី ៖ បាទ! អញ្ចឹងខ្ញុំអរគុណលោកយាយច្រើន។

វ៉ាន់ ៖ ចា៎ស!

“ចប់”